ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៧៦ សសរ

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតក្រុមការងារពិសេសរបស់នាយករដ្ឋមន្ត្រីលើកិច្ចការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយពាក់ព័ន្ធនឹង សេដ្ឋកិច្ចក្រៅប្រព័ន្ធ សហគ្រាសធុនមីក្រូ តូច និងមធ្យម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្ដីពីរៀបចំនិងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន
- បានឃើញអនុក្រឹត្យលេខ២៧៦ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការបង្កើតខុទ្ទកាល័យឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្ដីសម្រេចលេខ១៤៨ សសរ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្ដីពីការបង្កើតក្រុមការងារពិសេសរបស់នាយករដ្ឋមន្ត្រីលើកិច្ចការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងសហគ្រាសធុនមីក្រូ តូច និងមធ្យម
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ ..**

ត្រូវបានបង្កើតក្រុមការងារពិសេសរបស់នាយករដ្ឋមន្ត្រីលើកិច្ចការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធ សហគ្រាសធុនមីក្រូ តូច និងមធ្យម ចំណុះខុទ្ទកាល័យនាយករដ្ឋមន្ត្រី ដែលមានសមាសភាពដូចខាងក្រោម៖

១. ឯកឧត្តមបណ្ឌិត **ម៉ឹង មករា** ប្រធាន

២. ឯកឧត្តមបណ្ឌិត **សួន ណាយ** អនុប្រធាន
៣. ឯកឧត្តម **លី ហ៊ុយ** អនុប្រធាន
៤. ឯកឧត្តម **អ៊ុំ ឫទ្ធី** អនុប្រធាន
៥. លោកជំទាវ **ហេង ស្រីសរ** អនុប្រធាន
៦. លោក **លុយ បញ្ញា** សមាជិក
៧. លោក **យន់ សុវណ្ណារិទ្ធិ** សមាជិក
៨. លោកបណ្ឌិត **អ៊ុំ ចាន់ចំណាន** សមាជិក
៩. លោក **យន់ សុផាត** សមាជិក
១០. លោកស្រីបណ្ឌិត **ព្រហ្ម សុតា** សមាជិក
១១. លោកស្រី **ហ៊ីង សោភ័ណ្ឌា** សមាជិក
១២. លោក **ឌួង រតនា** សមាជិក។

ការតែងតាំង និងការផ្លាស់ប្តូរសមាសភាពនៃក្រុមការងារពិសេសរបស់នាយករដ្ឋមន្ត្រីលើកិច្ចការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធ សហគ្រាសធុនមីក្រូ តូច និងមធ្យម ត្រូវធ្វើឡើងតាមការសម្រេចរបស់នាយករដ្ឋមន្ត្រី ដោយយោងតាមសំណើរបស់ប្រធានក្រុមការងារ។

ក្រុមការងារពិសេសរបស់នាយករដ្ឋមន្ត្រីលើកិច្ចការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធ សហគ្រាសធុនមីក្រូ តូច និងមធ្យម អាចបង្កើតក្រុមការងារចំណុះតាមការចាំបាច់ តាមការសម្រេចរបស់នាយករដ្ឋមន្ត្រី ដោយយោងតាមសំណើរបស់ប្រធានក្រុមការងារ ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន។

**ប្រការ២ ..**

ក្រុមការងារពិសេសរបស់នាយករដ្ឋមន្ត្រីលើកិច្ចការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធ សហគ្រាសធុនមីក្រូ តូច និងមធ្យម មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ធ្វើជាសេនាធិការជូននាយករដ្ឋមន្ត្រីក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ដែលពាក់ព័ន្ធនឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធ សហគ្រាសធុនមីក្រូ តូច និងមធ្យម ដើម្បីបង្កើតបរិយាកាសអំណោយផលបន្ថែមទៀតសម្រាប់សេដ្ឋកិច្ចក្រៅប្រព័ន្ធ សហគ្រាសធុន មីក្រូ តូច និងមធ្យម ឱ្យរីកចម្រើន ប្រកបដោយនិរន្តរភាព និងចីរភាព ក្នុងការរួមចំណែក អភិវឌ្ឍន៍ ដល់សេដ្ឋកិច្ចជាតិ
- ចងក្រងជំនួយស្មារតី និងលើកវិធានការចាំបាច់ថ្មីៗជូននាយករដ្ឋមន្ត្រីលើការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ អភិវឌ្ឍន៍សេដ្ឋកិច្ចក្រៅប្រព័ន្ធ សហគ្រាសធុនមីក្រូ តូច និងមធ្យមឱ្យមានប្រសិទ្ធភាពខ្ពស់
- ធ្វើការជាមួយក្រសួង-ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងបណ្តាភាគីពាក់ព័ន្ធ ដើម្បីទទួលបានទិន្នន័យ ព័ត៌មាន និងរបាយការណ៍ ជូននាយករដ្ឋមន្ត្រី
- អនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់ពីនាយករដ្ឋមន្ត្រី។

**ប្រការ៣ ..**

ក្រុមការងារពិសេសរបស់នាយករដ្ឋមន្ត្រីលើកិច្ចការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធ សហគ្រាសធុនមីក្រូ តូច និងមធ្យម មានថវិកាសម្រាប់ដំណើរការការងាររបស់ខ្លួន ក្នុងកញ្ចប់ថវិការបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី។

**ប្រការ៤ ..**

សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ៨៣ សសរ ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការបង្កើតក្រុមការងារពិសេសរបស់នាយករដ្ឋមន្ត្រីលើកិច្ចការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងសហគ្រាសធុនមីក្រូ តូច និងមធ្យម និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៨ កើត ខែ ភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ